## ជំនួយលើការធ្វើដំណើរ

គម្រោងដឹកជញ្ជូនជំនួយដល់អ្នកជំងឺ (PATS) ជួយផ្តល់ជំនួយហិរញ្ញវត្ថុមួយផ្នែកសម្រាប់ការធ្វើដំណើរ និងកន្លែងស្នាក់នៅសម្រាប់មនុស្សដែលរស់នៅក្នុងតំបន់ជនបទរដ្ឋអូស្ត្រាលីខាងត្បូង ដែលត្រូវការធ្វើដំណើរលើសពី 100 គីឡូម៉ែត្រក្នុងមួយផ្លូវដើម្បីទៅជួបគ្រូពេទ្យឯកទេស។ ប្រភេទឯកទេសត្រូវបានចុះបញ្ជីជាមួយ Rural Support Service (សេវាកម្មគាំទ្រតាមជនបទ) នៃ SA Health។ PATS បានប្រមូលរៀបចំតាមលំដាប់នូវជម្រើសនានានៅក្នុងការដឹកជញ្ជូនទូទៅ និងព័ត៌មានដើម្បីជួយមនុស្សដែលរស់នៅទីកន្លែងនៅតាមតំបន់នានាឱ្យចូលរួមក្នុងសេវាកម្ម និងការណាត់ផ្នែកវេជ្ជសាស្ត្រនានា។
សម្រាប់ព័ត៌មានបន្ថែម សូមមើលកូដ QR នៅចុងបញ្ចប់។

## សម្រាប់ព័ត៌មានបន្ថែម

### វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV

បញ្ជីឈ្មោះវេជ្ជបណ្ឌិតពិនិត្យរោគទូទៅ (វេជ្ជបណ្ឌិត) ទាំងអស់ដែលអាចគ្រប់គ្រងមេរោគ HIV និងចេញវេជ្ជបញ្ជាថ្នាំសម្រាប់មេរោគ HIV នៅក្នុងប្រទេសអូស្ត្រាលី។ អ្នកអាចស្វែងរកតាមទីតាំង និងតាមភាសាដែលនិយាយ។

www.ashm.org.au/HIV/HIV-prescribers

### ការរុករកមិត្តភក្តិដែលមានមេរោគ HIV

ការរុករកមិត្តភក្តិនៅ SAMESH ភ្ជាប់មនុស្សដែលកំពុងរស់នៅមានមេរោគ HIV ទៅកាន់មិត្តភក្តិដែលបានទទួលការបណ្តុះបណ្តាល ដែលផ្តល់ការគាំទ្រ ការណែនាំ និងការតស៊ូមតិដើម្បីជួយពួកគេស្វែងរកការថែទាំសុខភាព កសាងទំនាក់ទំនងសង្គម និងទទួលបានសេវាកម្មនានាដែលលើកកម្ពស់ការផ្តល់សិទ្ធិអំណាច និងសុខុមាលភាព។

samesh.org.au/services/hiv-peer-navigation/

### គ្រោងការណ៍ដឹកជញ្ជូនជំនួយដល់អ្នកជំងឺ (PATS)

ផ្តល់ប្រាក់ឧបត្ថម្ភមួយផ្នែកដើម្បីទូទាត់ថ្លៃចំណាយក្នុងការធ្វើដំណើរ និងកន្លែងស្នាក់នៅសម្រាប់មនុស្សដែលរស់នៅតាមតំបន់ជនបទនៃរដ្ឋអូស្ត្រាលីខាងត្បូង។

https://www.pats.sa.gov.au/

ខ្លឹមសារនេះត្រូវបានកែសម្រួលដោយមានការអនុញ្ញាតពី Queensland Positive People’s Peer Navigation Program។ ការរចនាឡើងវិញ និងផលិតកម្មត្រូវបានចែករំលែកដោយមានការអនុញ្ញាតពី Living Positive Victoria’s Health Promotion Program។

SA Health បានចូលរួមវិភាគទានជាមូលនិធិសម្រាប់កម្មវិធីនេះ



# ការពិត

# ការយល់ដឹងអំពីប្រព័ន្ធសុខាភិបាលអូស្ត្រាលី

Khmer | ខ្មែរ

## ការស្វែងរកវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV (វីរុសបង្កឱ្យកើតជំងឺអេដស៍)

អ្នកត្រូវការវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ម្នាក់ដើម្បីជួយអ្នកគ្រប់គ្រង និងព្យាបាលមេរោគ HIV របស់អ្នក។ មានតែវេជ្ជបណ្ឌិតដែលបានទទួលការបណ្តុះបណ្តាលពិសេសប៉ុណ្ណោះដែលអាចធ្វើកិច្ចការនេះបាន។ ប្រសិនបើវេជ្ជបណ្ឌិតដែលបានធ្វើតេស្ត និងធ្វើរោគវិនិច្ឆ័យអ្នក មិនមែនជាវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ទេនោះ អ្នកនឹងត្រូវបញ្ជូនទៅវេជ្ជបណ្ឌិតដែលមានការបណ្តុះបណ្តាលផ្នែកព្យាបាលមេរោគ HIV។ អ្នកនៅតែអាចទៅជួបវេជ្ជបណ្ឌិតរបស់អ្នកសម្រាប់បញ្ហាសុខភាពផ្សេងទៀត ប្រសិនបើអ្នកចង់។ វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ត្រូវបានបណ្តុះបណ្តាលក្នុងការគ្រប់គ្រង និងព្យាបាលមេរោគ HIV ហើយជាវេជ្ជបណ្ឌិតតែមួយគត់ដែលអាចចេញវេជ្ជបញ្ជាការព្យាបាលមេរោគ HIV។ អ្នក មានសិទ្ធិជ្រើសរើសវេជ្ជបណ្ឌិតឯកទេសព្យាបាលមេរោគ HIV របស់អ្នក។

### វេជ្ជបណ្ឌិតឯកទេសព្យាបាលមេរោគ HIV អាចជា៖

- អ្នកឯកទេសជំងឺឆ្លងនៅមន្ទីរពេទ្យ
- វេជ្ជបណ្ឌិតនៅគ្លីនិកសុខភាពផ្លូវភេទ
- វេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GPs) ដែលបានទទួលការបណ្តុះបណ្តាលក្នុងការព្យាបាល និងការគ្រប់គ្រងមេរោគ HIV ជាទូទៅគេហៅពួកគាត់ថា វេជ្ជបណ្ឌិតចេញវេជ្ជបញ្ជា S100

### តួនាទីរបស់វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV របស់អ្នក

វេជ្ជបណ្ឌិតរបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បីគ្រប់គ្រង និងព្យាបាលមេរោគ HIV របស់អ្នក និងរក្សាអ្នកឱ្យមានសុខភាពល្អ។

### ការទៅជួបវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ជាលើកដំបូងរបស់អ្នក

នៅក្នុងការទៅជួបលើកដំបូងរបស់អ្នក វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV

- ធ្វើតេស្តប្រព័ន្ធភាពស៊ាំរបស់អ្នក (ការរាប់ចំនួនកោសិកា CD4)
- ពិនិត្យសុខភាពទូទៅរបស់អ្នក
- ធ្វើតេស្តឈាមលើចំនួនវីរុស
- ពិនិត្យមើលភាពធន់នឹងការព្យាបាល។

ពួកគេក៏នឹងនិយាយជាមួយអ្នកអំពីសុខភាពទូទៅរបស់អ្នក ស្ថានភាពសុខភាពផ្សេងទៀត និងការគាំទ្រណាមួយដែលអាចជួយអ្នក ក្នុងការធ្វើរោគវិនិច្ឆ័យថ្មីរបស់អ្នកផងដែរ។

### ការចេញវេជ្ជបញ្ជាឱសថរបស់អ្នក

នេះត្រូវបានណែនាំឱ្យអ្នកចាប់ផ្តើមការព្យាបាល ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានទទួលការធ្វើរោគវិនិច្ឆ័យមេរោគ HIV រួច។ នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់មនុស្សដែលមានចំនួនកោសិកា CD4 ទាប អ្នកដែលមានស្ថានភាពសុខភាពផ្សេងៗទៀតទាក់ទងនឹងមេរោគ HIV និងអ្នកដែលមានផ្ទៃពោះ។ វេជ្ជបណ្ឌិតរបស់អ្នកនឹងពិភាក្សាអំពីការព្យាបាលជាមួយអ្នក ដើម្បីរកមើលថាតើឱសថមួយណា ត្រឹមត្រូវសម្រាប់អ្នក។

### តាមដានសុខភាពរបស់អ្នក

វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV របស់អ្នក នឹងពិនិត្យសុខភាពរបស់អ្នកដោយការធ្វើតេស្តឈាមទៀងទាត់។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នក ថាតើអ្នកត្រូវការជួបពួកគេញឹកញាប់ប៉ុណ្ណាដែរ។ ដំបូងអ្នកប្រហែលជាទៅជួបពួកគាត់ញឹកញាប់ ប៉ុន្តែនេះនឹងត្រូវកាត់បន្ថយទៅតាមពេលវេលា (រៀងរាល់3-ខែ 6ខែ ឬប្រចាំឆ្នាំ)។ សម្រាប់ព័ត៌មានបន្ថែម សូមមើល ប័ណ្ណការពិតស្តីពីការតាមដានសុខភាពរបស់អ្នក។

### ការជ្រើសរើសវេជ្ជបណ្ឌិតដែលត្រឹមត្រូវសម្រាប់អ្នក

វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកវេជ្ជបណ្ឌិតម្នាក់ដែលអ្នកអាចនិយាយជាមួយ និងជឿទុកចិត្តបាន និងធ្វើការរួមគ្នាជាមួយក្រុមថែទាំសុខភាពមេរោគ HIV របស់អ្នក។ ក្រុមថែទាំសុខភាពមេរោគ HIV របស់អ្នក អាចរួមមានវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV, គិលានុបដ្ឋាក HIV, peer navigator (អ្នកលើកទឹកចិត្តអ្នកដទៃដែលស្ថិតក្នុងស្ថានភាពស្រដៀងគ្នា) អ្នកចិត្តសាស្ត្រ បុគ្គលិកសង្គមកិច្ច ឬអ្នកប្រឹក្សាយោបល់ និងបុគ្គលិកសុខាភិបាលផ្សេងទៀត។

ប្រសិនបើអ្នកកំពុងជួបវេជ្ជបណ្ឌិតម្នាក់ដែលអ្នកមិនមានអារម្មណ៍ត្រឹមត្រូវ អ្នកអាចផ្លាស់ប្តូរវេជ្ជបណ្ឌិតបាន។ អ្នកក៏អាចផ្លាស់ប្តូររវាងមន្ទីរពេទ្យ គ្លីនិកសុខភាពផ្លូវភេទ និងគ្លីនិក GP ឬស្នើសុំផ្លាស់ប្តូរវេជ្ជបណ្ឌិតនៅក្នុងគ្លីនិកទាំងនេះបាន។ វាជាជម្រើសរបស់អ្នកទេ។

អ្នកខ្លះមានវេជ្ជបណ្ឌិតពីរនាក់ វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV និង GP សម្រាប់សុខភាពទូទៅ។ អ្នកផ្សេងទៀតមាន GP ចេញវេជ្ជបញ្ជា S100 ដែលពួកគេទៅជួបសម្រាប់ពិនិត្យមេរោគ HIV ក៏ដូចជាសុខភាពទូទៅរបស់ពួកគេផងដែរ។ ប្រសិនបើអ្នករស់នៅក្រៅទីក្រុងមែលប៊ន អ្នកប្រហែលជាមានជម្រើសតិចជាងអំពីការថែទាំមេរោគ HIV នៅក្នុងតំបន់របស់អ្នក។ អ្នកក៏អាចព្រួយបារម្ភអំពីរឿងសម្ងាត់ផ្ទាល់ខ្លួនផងដែរ។ SAMESH Peer Navigators អាចជួយកំណត់សេវាកម្មដែលសាកសមសម្រាប់អ្នក។

### អ្វីដែលត្រូវប្រាប់ក្រុមថែទាំសុខភាពរបស់អ្នក

- អារម្មណ៍ដែលអ្នកកំពុងមាន
- ឱសថផ្សេងទៀតដែលអ្នកកំពុងប្រើ (រួមទាំងឱសថដែលមិនមានវេជ្ជបញ្ជា និងថ្នាំបំប៉ននានា)
- អ្វីដែលអ្នកបរិភោគ និងផឹក កាហ្វេអ៊ីន និងគ្រឿងស្រវឹង ការប្រើប្រាស់គ្រឿងញៀន និងថ្នាំជក់
- ការផ្លាស់ប្តូរ ឬកង្វល់ណាមួយ ផលប៉ះពាល់ លំនាំនៃការគេង អារម្មណ៍

### អ្វីដែលត្រូវសួរក្រុមថែទាំសុខភាពរបស់អ្នក

- តើខ្ញុំគួរចាប់ផ្តើមការព្យាបាលមេរោគ HIV ឬទេ (ប្រសិនបើអ្នកមិនទាន់បានចាប់ផ្តើម)?
- តើខ្ញុំគួររកមើលផលប៉ះពាល់អ្វីខ្លះ?
- តើអ្វីជាចំនួនវីរុសរបស់ខ្ញុំ (បរិមាណវីរុសក្នុងឈាមរបស់ខ្ញុំ)?
- តើការរាប់ចំនួនកោសិកា CD4 របស់ខ្ញុំជាអ្វី (មុខងារប្រព័ន្ធភាពស៊ាំ)?
- តើការព្យាបាលរបស់ខ្ញុំដំណើរការទេ? តើខ្ញុំត្រូវការផ្លាស់ប្តូរអ្វីទេ?
- តើមានអ្វីដែលខ្ញុំកំពុងលេប ឬប្រើ អាចមានប្រតិកម្មជាមួយនឹងការព្យាបាលរបស់ខ្ញុំទេ?
- តើខ្ញុំអាចកែលម្អសុខភាព និងសុខុមាលភាពរបស់ខ្ញុំដោយរបៀបណា?